**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**

**Ministry of Environment**

លេខៈ ១៧៩ ប.ស្ថ

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១០

# ប្រកាស

## ស្តីពីការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ "អូរបញ្ញា" ភូមិគាន្ធាក ភូមិព្រេច ភូមិវាលចាស់ និងភូមិស្រែវាល ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ក្នុងដែនជម្រកសត្វព្រៃបឹងពែរ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន

- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី តំបន់ការពារធម្មជាតិ

-បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៨ ស្តីពីការតម្លើងនាយកដ្ឋានការពារ-អភិរក្សធម្មជាតិ របស់ក្រសួងបរិស្ថាន ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ

-តាមតម្រូវការចាំបាច់របស់សហគមន៍មូលដ្ឋាន។

## សំរេច

**ប្រការ ១ :** រៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ **"អូរបញ្ញា"** ដែលស្ថិតនៅក្នុងភូមិគាន្ធាក ភូមិព្រេច ភូមិវាលចាស់ និងភូមិស្រែវាល ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ នៃដែនជម្រកសត្វព្រៃបឹងពែរ។

**ប្រការ ២ :** សហគមន៍តំបន់ការពារធម្មជាតិ " **អូរបញ្ញា** " ក្នុងដែនជម្រកសត្វព្រៃបឹងពែរ មានផ្ទៃដីទំហំ **៥៦១៨ហិចតា** បានកំណត់ទីតាំងព្រំប្រទល់ក្នុងផែនទីដែលមានអាប់ស៊ីស និងកូអ័រដោនេ ដូចខាងក្រោម :

| ចំណុច | អាប់ស៊ីស X | កូអ័រដោនេ Y | ចំណុច | អាប់ស៊ីស X | កូអ័រដោនេ Y |
|---|---|---|---|---|---|
| A | 476547 | 1466486 | G | 483532 | 1466334 |
| B | 478088 | 1466198 | H | 483519 | 1457617 |
| C | 478313 | 1466339 | I | 479323 | 1459268 |
| D | 479597 | 1466523 | J | 479373 | 1454567 |
| E | 480123 | 1466614 | K | 477170 | 1456927 |
| F | 482532 | 1466381 | L | 477547 | 1462012 |

**ប្រការ ៣ :** ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ " **អូរបញ្ញា** " នៃដែនជម្រកសត្វព្រៃបឹងពែរ និងការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់នេះ ត្រូវចុះកិច្ចព្រមព្រៀងជាមួយរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន ហើយសហគមន៍ត្រូវមានលក្ខន្តិកៈ និងផែនការគ្រប់គ្រង ស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានពាក់ព័ន្ធ កម្រងតំបន់ការពារធម្មជាតិស្ទឹងសែន មន្ទីរបរិស្ថានខេត្តព្រះវិហារ ដែនជម្រកសត្វព្រៃបឹងពែរ និងសហគមន៍តំបន់ការពារធម្មជាតិ " **អូរបញ្ញា** " នៃដែនជម្រកសត្វព្រៃបឹងពែរ ត្រូវសហការអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាទៅ ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

មុខ_ម៉ារឹទ

បណ្ឌិត.ជីវិទ្យា

<u>ចម្លងជូន:</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-សាលាខេត្តកំពង់ធំ
-ឯកសារ-កាលប្បវត្តិ